# ការសំភាសន៏របស់ហង្ស ចាន្នី

កៈ អ្នកធ្វើការសំភាសន៏ដោយថន រដ្ឋា ខៈ អ្នកដែលត្រូវបានគេសំភាសន៏ហង្ស ចាន្នី

## <u>អំពីជីវប្រវត្តិសង្ខេបរបស់អ្នកមីងហង្ស ចាន្នី</u>

បាទ! ថ្ងៃនេះគឺថ្ងៃទីប្រាំបួន ខែកុម្ភៈ ឆ្នាំពីរពាន់ដប់ប្រាំបី ហើយខ្ញុំបាទឈ្មោះ ថន រដ្ឋា នឹងសម្ភាសអ្នកមីង អើ អ្នកមិងហង្សចាន្នី ដែលបច្ចុប្បន្នអ្នកមីងរស់នៅក្នុងភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដោបង ខេត្តបាត់ដមបង
អញ្ចឹងថ្ងៃនេះខ្ញុំចង់សម្ភាសអ្នកមីងខ្លះៗអំពីជីវៈប្រវត្តិរបស់អ្នកមីងក៏ដូចជាសម្រាប់កូនចៅជំនាន់ក្រោយៗផងដែរបាទ។ក្រុមរបស់ខ្ញុំបាទគឺមកពីខាងប៊ីវ៉ាយូរនៅសហរដ្ឋអាមេរិចពួកនិស្សិតក៏ចង់រៀនអំពីប្រជាជនកម្ពុជាផងដែរ បាទ!
អញ្ចឹងជាដំបូងខ្ញុំចងសួរអំពីជីវប្រវត្តិសង្ខេបរបស់អ្នកមីង អ្នកមីងឈ្មោះពេញឈ្មោះអ្វីដែរ?

ខៈ ហង្សចាន្នីពិតប្រាកដម៉ង។

កៈ ហង្ស ចាន្នីណ៎ បាទ! អ្នកមីង អ្នកមីងមានឈ្មោះហៅក្រៅទេ?

ខៈ ឈ្មោះហៅក្រៅឈ្មោះស្រី បងឈ្មោះស្រី។

កៈ ហើយអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយ?

ខៈ ៥៣ហើយ។

កៈ ឆ្នាំខ្មែរឆ្នាំអីដែរអ្នកមីង?

ខៈ ឆ្នាំរោង។

កៈ ឆ្នាំរងណ៎ អ្នកមីងចាំថ្ងៃខែឆ្នាំកំនើតាំទេ?

ខៈ អត់ចាំផង ភ្លេចអស់ហើយ អត់ចាំផង។

កៈ បាទហើយអ្នកមីងទីកន្លែងកំណើតរបស់អ្នកមីងនៅឯណា?

ខ៖ ខេត្តកំពត ខេត្តខុះបងក្រាស ឃុំកោះតាច័ន្ទតាច័ន្ទ។

ក៖ ស្រុកអីដែរ?

ខ៖ ស្រុកកំពត។

ក៖ អឺ! អត់ទោសអ្នកមីងមានបងប្អូនប៉ុន្មានអ្នកដែរ?

ខ៖ ខ្ញុំមានប្រាំពីនាក់ស្លាប់អស់ពីនៅសល់ប្រាំ។

ក៖ អ្នកនៅសល់ប្រាំអ្នកឈ្មោះអីខ្លះ?

ខ៖ ឈ្មោះប៊ុនលី ឈ្មោះបងខន ឈ្មោះអំប្រុស ប៊ុនលី អាប្រុស បងខន ខ្ញុំចាំតែប៉ុន្នោះឯង។

ក៖ អ្នកមីងអាចរៀបរាប់អំពីកូនទីមួយគាត់នៅឯណាកំពុងធ្វើអីឥឡូវ?

ខ៖ កូនបងទីមួយធ្វើការនៅកន្លែងប្រពន្ធគេអត់ស្គាល់ផង។

ក៖ អ្នកទីពីរឈ្មោះអីគេ?

ខ៖ អ្នកទីពីឈ្មោះធឿន។

ក៖ ធ្វើការអីគេ?

ខ៖ ធ្វើការនៅស្រុកកំពុងត្រាចហ្មង។

ក៖ ខេត្តអីដែរ?

ខ៖ ខេត្ត កំពត។

ក៖ គាត់ប្រកបមុខរបរអីដែរ?

ខ៖ រកស៊ីចិញ្ចឹមកូនចិញ្ចឹមគ្រួសារគេអី។

ក៖ គាត់រកស៊ីអីគេអ្នកមីង?

ខ៖ អត់ដឹងផង។

កៈ អញ្ចឹងពួកគាត់ប្រកបមុខរបរធ្វើអីដែរ?

ខៈ កាលគាត់ស្លាប់ខ្ញុំនៅតូចហ្នឹង ខ្ញុំថាកាលនៅតូចៗឪពុកខ្ញុំគាត់អញ្ញាតបង្កងអញ្ជាត់បង្គា ពីដើមនៅតំបន់នោះចាញ់។

កៈ តើពួកគាត់ទាំងពីរគេជាមនុស្សបែបណា ស្លូត កាច?

ខៈ ស្លូតទាំងអស់ ស្លូតទាំងអស់។

កៈ ចងនិយាយពីឪពុកម្ដាយ?

ខៈ ឪពុកម្ដាយខ្ញុំស្លូតទាំងអស់។

កៈ អរគុណច្រើនទាក់ទងនៅក្នុងការរៀបរាប់អំពីរឪពុកម្ដាយ ហើយ។

ខៈ តាំងពីទូចមកខ្ញុំគ្មានឪពុកម្ដាយណាហៅពិតប្រាកដទេអត់
បើសិនជាមានឪពុកម្ដាយពិតប្រាកដ ខ្ញុំនឹងនៅបំរើគាត់មានគុណច្រើនជាង។

កៈ អញ្ចឹងអត់ដឹងថាគាត់ធ្វើអ្វីសម្រាប់ប្រកបមុខរបរចិញ្ចឹមជីវិត?

ខៈ អត់ដឹងផង។

កៈ មានចងចាំកាលពីកាត់នៅពីក្មេងៗទេ?

ខៈ ចងចាំកាលនៅក្មេងៗ។

កៈ កាលដែលៗ ចង់និយាយថាកាលពីគាត់នៅក្មេងៗគាត់មាននិទានរឿងអីប្រាប់អ្នកមីងទេ។

ខៈ អត់ដែលដឹងផង។

កៈ អគុណច្រើន។ អញ្ចឹងមានចាំឈ្មោះជីដូនជីតា?

ខៈ ស្គាល់។

កៈ គាត់ឈ្មោះអីដែរ?

ខៈ តាសន ឈ្មោះអ៊ំសន កើតនៅកំពុងត្រាចនេះដែរ។

កៈ បាទ!

ខៈ ឈ្មោះអ៊ំ កងទៀតប្រពន្ធរបស់គាត់។

កៈ តើពួកគាត់កើតនៅស្អីឯណា?

ខៈ កើតនៅស្អីឯណានោះខ្ញុំមិនបានចាំផង។

កៈ អញ្ចឹងអត់ចាំខេត្តទេណ៎?

ខៈ អត់ចាំផង គាត់ស្លាប់ទៀត កាលពីមុនគាត់ធ្វើគ្រូអាចារ្យខាង ពរលា ពលាការអីនោះគេមកមើលហើយ។

កៈ ធ្លាប់លឺគេនិយាយថាគាត់គឺជាគ្រូអាចារ្យណ៎?

ខៈ ចាស៎! គ្រូអាចារ្យ។

កៈ បាទ! អគុណច្រើនអ្នកមីង អញ្ចឹងខ្ញុំចង់សាកសួរអំពីក្រុមគ្រួសារបន្តិច តើអ្នកមីងនូវខេត្តនេះអស់រយៈពេលប៉ុន្មាន?

ខៈ ប្រហែលជា៥-៦-៧ឆ្នាំ។

កៈ បាទ! បន្ទាប់មករើមកនូវ។

ខៈ បាត់ដំបង។

កៈ បាត់ដំបង។អរគុណច្រើនអ្នកមីង អ្នកមីងមានសាច់ញ្ញាតិដែលរស់នៅក្រៅប្រទេសទេ?

ខៈ អត់មានទេ មានតែនៅក្នុងស្រុកខ្មែរនឹងឯង។

កៈ អញ្ចឹងទាក់ទងនឹងអាពាហ៍ពិពាហ៍វិញ អ្នកមីងរៀបអាពាហ៍បានរយៈពេលប៉ុន្មានឆ្នាំហើយ?

ខៈ អត់បានរៀបអាពាហ៍ពិពាហ៍ផង។

កៈ អញ្ចឹងបានន័យថាអ្នកមីងស្រលាញ់គ្នា។បាទ! ហើយមានផ្កាត់ខ្មោចអត់?

ហាង្ស ចាន្ធនី៖ មានខ្លះៗ

ក៖ សែនព្រេនអី?

ខ៖ មាន។

ក៖ ហើយអាហ្នឹងមានបណ្ណាការអត់?

ខ៖ អត់មានផង។

ក៖ ហើយជួយប្រាប់អំពីមូលហេតុថា ហេតុអីបានជយាអ្នកមីងស្រលាញ់លោកពូអញ្ចឹងណា៎ ជួបគ្នាដំបូងម្តេចទៅ?

ខ៖ ជួបគ្នាដំបូង ខ្ញុំក៏ហៅគេមកនៅផ្ទះខ្ញុំ យូរៗទៅក្លាយជាប្តីប្រពន្ធជាមួយគ្នាម្តងទៅ។

ក៖ ហើយចុះអ្នកមីងអត់មានប៉ាម៉ាក់?

ខ៖ ប៉ាម៉ាក់ខ្ញុំស្លាប់តាំងពីខ្ញុំនៅប៉ុន្មានខែ តាំងពីខ្ញុំនៅតូចៗម្លេះ មិនទាន់ដឹងអីផង មិនទាន់ដឹងក្តីផង។

ក៖ អេ៎! នៅជាមួយគ្នាគ្រាន់បានទីពឹងហ៎?

ខ៖ ចាស៎!

ក៖ បាទ! ឥឡូវមានកូនប៉ុន្មាននាក់ហើយ?

ខ៖ កូនខ្ញុំពីហើយ។

ក៖ កូនពីរនាក់ហ្ន៎?

ខ៖ ពីរនាក់អាមួយនៅស្រុក អាមួយនៅបាត់ដំបងនេះឯង។

ក៖ មានតែពីនាក់ប៉ុនហ្នឹងឯងអញ្ចឹងគាត់មានតែពីរនាកប៉ុនហ្នឹងឯង?

ខ៖ ចាស៎!

កៈ អញ្ចឹងអរគុណអ្នកមីងក្នុងការចែកចាយអំពីអើ
អាពាហ៍ពិពាហ៍នោះណ៎។ហើយចងសួរស្វាមីរបស់អ្នកមីងឈ្មោះអ្វីដែរ?

ខៈ ឈ្មោះមុនហ៎?

កៈ ស្វាមីដែលអ្នកមីងនិយាយថាអត់បានរៀបអាពាហ៍ ពិពាហ៍នោះណា ឈ្មោះអី?

ខៈ ឈ្មោះ ស៊ូ ចំរើន។

កៈ ឈ្មោះ ស៊ូ ចំរើនណ៎?

ខៈ ចាស៎!

កៈ បាទ! អគុណច្រើន ហើយចុះទាក់ទងនឹងភាសាវិញ
ក្រៅពីភាសារខ្មែរនាក់មីងមានចេះភាសសារអ្វីទៀតទេ?

ខៈ ខ្ញុំចេះភាសារអង់គ្លេសតិចទួចនោះណាស់។

កៈ ហើយអាចចេះនិយាយបានទេ?

ខៈ និយាយបាន។

កៈ សរសេរបានទេ?

ខៈ បើសរសេរអត់ចេះផង ខ្ញុំបានតែនិយាយប៉ុន្នឹងឯង។

កៈ បាទ! អរគុណច្រើននាកមីង អញ្ចឹងទាក់ទងនឹងខ្សែរជីវិត្តរបស់អ្នកមីង នាក់មីងអើ
ចាប់ផ្តើមធំហើយពេញវ័យហើយនោះណ៎ នៅក្មេងផងដែរ នាក់មីងរៀននៅសាលាណាដែរ?

ខៈ សាលានៅត្រពាំងអំពៅ។

កៈ ខេត្ត។

ខៈ ខេត្ត កំពត។

កៈ ខេត្ត កំពត?

ខ៖ ចាស៎!

ក៖ ហើយនាក់មីងមានមិត្តិភក្តិទេ?

ខ៖ អត់ដែលមានផង?

ថនរដ្ឋា៖ អត់ដែរមានផង។

ក៖ ចុះពេលធំឡើង?

ខ៖ ធមឡើងក៏អត់ដែលមាន។

ក៖ អើ អត់មានម្នាក់ទេណ៎?

ខ៖ ខ្ជិលយកពួកម៉ាក ខ្ជិលហ្មងមិនដឹងយកធ្វើអី។

ក៖ បាទ! នៅចាំឈ្មោះគាត់ទេ?

ខ៖ អត់ចាំផង។

ក៖ អរគុណច្រើន កាលពីមុនអ្នកមីងនៅជនបទឬក៏នៅទីក្រុង?

ខ៖ នៅជនបទ។

ក៖ មុខរបរវិញធ្វើអីដែរ?

ខ៖ ធ្វើស្រែធ្វើភ្លឺងឹងគេនឹងឯងដែរនោះ ច្រូតកន្ដាប់។

ក៖ ច្រូតស្រូវច្រូតអីទៅណ៎?

ខ៖ ចាស!

ក៖ អញ្ចឹងក្រៅពីការងារស្រែចំការអ្នកមីងបានធ្វើអ្វីខ្លះសម្រាប់ចិញ្ចឹមជីវិត?

ខ៖ ខ្ញុំនៅភ្នំពេញខ្ញុំចូលធ្វើការសន្តិសុខ។

ក៖ បាទ!

ហង្ស ចាន្ទី៖ ប្រាក់ខែបានមួយរយជាងដែរ។

ក៖ បាទ!

ហង្សចាន្ទី៖ តែមិនដឹងធ្វើមេចកមតាមមិត្តិភក្តិនៅផ្សារពោងល្វេននេះលុងនៅបាត់ដំបងអញ្ចឹងទៅ។

ក៖ ហើយផ្ទះនេះ ផ្ទះរបស់អ្នកមីង?

ខ៖ ចាស! ក៏ប៉ុនតែប៉ាអានេះ។

ក៖ អេាំ! មីងនៅនេះប៉ុន្មានឆ្នាំហើយ?

ហង្ស ចាន្ទី៖ នៅ៤-៥ឆ្នាំឥឡូវហើយ។

ក៖ បាទ! អញ្ចឹងតាំងពីក្មេងមកដល់ឥឡូវនេះគ្រួសាររបស់អ្នកមីងក៏ដូចជានាក់មីងមានការផ្លាស់ប្រែអីទេ?

ហង្ស ចាន្ទី៖ ប្រែទាំងអស់។

ក៖ ប្រែយ៉ាងមេចទៅ?

ក៖ អតដឹងគេមេចៗផងនៅឆ្ងាយពីគ្នា ខ្ញុំមេចដឹង។

ក៖ ចុះសម្រាប់អ្នកមីងមានអារម្មណ៍ថាខ្លួនឯងមានការផ្លាស់ប្រែអីទេ?

ខ៖ អត់ផងមិនដែល។

ក៖ នៅដដែលណាំ?បាទ! ការរស់នៅសុខភាពអីដដែលៗណាំ?

ខ៖ ដដែលៗ។

កៈ បាទ! អរគុណច្រើន។អញ្ចឹងសូមតទៅទៀតអ្នកមីង អើទាក់ទងនិងម្ហូប អ្នកមីងចូលចិត្តម្ហូបអីដែរ?

ហាង្សចាន្ទីៈ ម្ហូប ចល័តម៉ងនឹង។

កៈ អីគេនាក់មីអ។

ខៈ ចល័តម៉ង មានអីត្រូវស្ងោរៗ ត្រូវឆារៗ ត្រូវចៀនៗ។

កៈ បាទ!ៗ

ខៈ មានតែប៉ុន្នឹងឯងរាល់ងៃ។

កៈ បានន័យថាស្អីក៏ញុំាបានដែរណ៎?

ខៈ ស្អីក៏ញុំាបានអោយតែឆ្អិន។

កៈ ហើយកាលនៅក្មេង នាក់មីងចូលចិត្តលេងកីឡាអីដែរ?

ខៈ អត់ធ្លាប់លេងផង។

កៈ ចុះល្បែងប្រជាប្រិយអីនុះ។

ខៈ អត់លេងផង ស្រាក៏មិនផឹកល្បែងក៏មិនលេងដែរ។

កៈ ទាក់ទងនឹងចំរៀងវិញនាក់មីងចូលចិត្តចំរៀងដែរទេ?

ខៈ ចូលចិត្ត ចូលចិត្តខារ៉ាអូខេ។

កៈ ការ៉ាសអូខេបទអីគេ?

ខៈ បទពីដើម។

កៈ បទអីដែរនាក់មីង?

ខៈ បទស៊ីន ស៊ីសាម៉ុត ប៉ែន រ៉ន អីនេះឯង។

កៈ អត់ចាំទេ?

ខៈ អត់ចាំផង។

កៈ អញ្ចឹងបងប្អូនរបស់អ្នកមីង អ្នកមីងកាត់មានចេះលេងឧបក្ខរណ៍តន្ត្រីទេ?

ហង្ស ចាន្ទីៈ មានបងខ្ញុំទីមួយលេងល្ខោនបាសាក់។

កៈ លេងល្ខោនបាសាក់ណ៎?

ហង្ស ចាន្ទីៈ ចាស៎!

ថន រដ្ឋាៈគាត់ចេះស្គរចេះអីណ៎?

ខៈ ចេះ។

កៈ ខ្ញុំចង់សួរផ្ទះវិញ ផ្ទះកាលពីមុនមានលក្ខណបែបណាដែរ?

ខៈ មានលក្ខណផ្ទះឈើ។

កៈ ផ្ទះឈើណ៎ប្រក់ស្លឹក?

ហង្ស ចាន្ទីៈ ប្រក់ស្លឹក ជញ្ជាំងស្លឹក។

កៈ ជញ្ជាំងស្លឹកដែរណ៎?

ហង្ស ចាន្ទីៈចាស៎!

កៈ ហើយសរសរ សរសរអីគេ?

ខៈ សរសរនៅស្រុកស្រែដឹងស្រាប់ហើយ។

កៈ បាទ! សរសរឈើ សរសរថ្ម?

ខៈ សរសរឈើ។

កៈ សរសរឈើណ៎?

ខ៖ ចាស!

ក៖ ហើយអ្នកណានាក់សាងសង់ផ្ទះហ្នឹង?

ខ៖ ឪពុកខ្ញុំ។

ក៖ គាត់នាក់សាងសង់ផ្ទាល់ណា៎?

ខ៖ សាងសង់ផ្ទាល់។

ក៖ ហើយគាត់ចេះសាងសង់ពីណាមកដែរ?

ហាង្សជាន្ទី៖ អត់ដឹងផង ដឹងថាធំឡើងមានផ្ទះនៅម៉ង។

ក៖ បាទ! នាក់មីងមានបានរៀនអ្វីតពីឪពុកម្តាយរបស់មីងទេ ដូចជារៀនជំនាញអីអញ្ចឹងណា៎?

ខ៖ អត់ផង អត់ដែលធ្លាប់ផង។

ក៖ បាទ! ចំឡើយល្អ
ហើយអញ្ចឹងទាក់ទងនឹងបញ្ហានៅក្នុងជីវិត្តវិញនាក់មីងតាំងពីដឹងក្តីរហូតមកដល់បច្ចុប្បន្ននេះ
នាក់មីងធ្លាប់ជួបឧប្បសគ្គធំនៅក្នុងជីវិតទេ?

ខ៖ ជួបក៏ជួបញឹកញាប់។

ថនរដ្ឋា៖ អីគេទៅ?

ខ៖ ដឹងអីទេខ្ញុំភ្លេចបាត់អស់ហើយអត់ចាំផង។

ក៖ ចាំឬក៏មានសម័យណាមួយដែលធ្វើអោយមីងពិបាកឬក៏ពេលមួយធ្វើអោយពិបាកខ្លាំង?

ខ៖ ពិបាកៗ ពិបាកពេកហើយ។

ក៖ ពេលណា?

ខ៖ ពេលហ្នឹង។

ក៖ ពេលណា?

ខ៖ ពេលឥឡូវនេះ។

ថន រដ្ឋា៖ ពិបាកយ៉ាងមេចទៅនាក់មីង?

ខ៖ ទីមួយអត់មានអង្ករ ទិពីរមើលផ្ទះមើល តែប៉ុននោះឯងអត់មានលុយចាយ អត់មានលុយទិញអីៗណាស។

ក៖ អគុណច្រើន ហើយអ្នកមីងគឹតថានឹងអាចឆ្លងកាតឧបសគ្គនេះដោយរបៀបណាទេ?

ខ៖ ខ្ញុំអត់ដឹងផង។

ក៖ អត់ដឹងទេណ៎។

ខ៖ ចាស!

ក៖ អត់មានវិធីដើម្បីដោះស្រាយទេណ៎?

ខ៖ អត់។

ថន រដ្ឋា៖ បាទ! អរគុណនាក់មីង។ហើយទាក់ទងនឹងបទពិសោធល្អៗតាំងពីមុនមក នាកមីងធ្លាប់មានអ្វីដែលជាបទពិសោធន៏ល្អៗធ្វើអោយនាក់មីងចងចាំទេ?

ខ៖ អត់ធ្លាប់ផង។

ក៖ អត់ទេណ៎?

ខ៖ អត់។

ក៖ អញ្ជឹងខ្ញុំចង់ជម្រាបទៅកាន់នាក់មីងថា
អើសាកលវិទ្យាល័យ(ប៊ីវ៉ាយយូ)គឺជាសាកលវិទ្យាល័យមួយនៅសហរដ្ឋអាមេរិច
ហើយអញ្ជឹងសកលវិទ្យាល័យនេះបានរៀបចំជាក្រុមមួយដើម្បីរក្សានូវប្រវត្តិរូបសង្ខេបអញ្ជឹង
ណាស់
សម្រាប់ទុកអោយប្រជាជនខ្មែររបស់យើងមានប្រវត្តិរូបឬក៏ចែកចាយបទពិសោធន៍ផ្ទាល់ខ្លួន
ផ្សេងៗ អញ្ជឹងអើពួកខ្ញុំមានប្រធាន ខ្ញុំមានប្រធាននៅប្រចាំនៅតំបន់របស់ខ្ញុំនោះណា។

ខ៖ ចាស៎!

ថន វដ្ឋា៖ គាត់ឈ្មោះថា (ថូម៉ាស)
ហើយឥឡូវគាត់រៀននៅអាមេរិចប៉ុនតែគាត់ព្យាយាមជួយប្រជាពលរដ្ឋខ្មែរដើម្បីអោយគាត់អាចថែរក្សាប្រវត្តិរូបរបស់គាត់សង្ខេបអញ្ចឹងណាស។បាទ!
ហើយនៅក្នុងការសម្ភាសនេះខ្ញុំនឹងទុក អើជា(ស៊ីឌី)សម្រាប់អ្នកមីងមួយ
ហើយមួយទៀតនៅ(វ៉ែបសាយ) ហើយអត្តសញ្ញាណប័ណ្ណរបសនាក់មីងអាចវាយឈ្មោះបាន
ហើយបើអ្នកមីងចង់
កូនចៅជំនាន់ក្រោយចងមើលឈ្មោះរបស់នាក់មីងយកអត្តសញ្ញាណប័ណ្ណទៅវាយចូលក្នុង(វ៉ែបសាយ)មយយដែលខ្ញុំនឹងអោយនឹង ហើយបន្ទាប់មកនឹងឃើញសម្លេញ
ឃើញរូបថតដែលខ្ញុំបានតថនឹងណាស។

ខ៖ ចាស៎!

ក៖ ហើយគេអាចលឺសម្លេងថានាក់មីងមានប៉ាម៉ាក់ជីដូនជីតា បងប្អូន
ប៉ុន្មាននាក់ៗអញ្ចឹងណាស។

ខ៖ ចាស៎!

ក៖ អញ្ចឹងគេអាចដឹងតាមសម្លេងមយយហ្នឹង អញ្ចឹងអគុណច្រើននាក់មីង
អញ្ចឹងជាចុងក្រោយនាក់មីងមានពាក្យអីផ្តាំផ្ញើសម្រាប់កូនចៅជំនាន់ក្រោយឬក៏មានមតិយោបល់អីបន្ថែមអញ្ចឹងណាស។បាទ នាក់មីងមានការផ្តាំផ្ញើរអីទេ?

ខ៖ ដូចជាមិនដឹងនិយាយអីទេខ្ញុំនេះ។

ក៖ ដូចជាអោយអាអូនតូចទៅអនាគតចងអោយគាត់។

ខ៖ ចង់អោយល្អដើលេងជាមួយមិត្តិភក្តិល្អៗ។

ថន វដ្ឋា៖ រាប់អានមិត្តភក្តិល្អៗ។

ខ៖ ចាស៎!

ថន រដ្ឋា៖ ហើយចងអោយគាត់ទៅសាលាអត់?

ខ៖ ចង់តើ!

ថន រដ្ឋា៖ ទៅរៀនផ្នែកអីទៅ?

ខ៖ អក្សរម៉ង ថ្នាក់ទីមួយម៉ង ធំឡើងចូលថ្នាក់ទីមួយម៉ងនោះណាស់។

ក៖ ហើយចង់អោយកាត់ក្លាយទៅជាអីទៅថ្ងៃអនាគត?

ខ៖ អនាគតដោយសាវារករបរ វាចេះដឹងទៅវារកស៊ីចិញ្ចឹមឪពុកម្តាយ ក្លាចតែចិញ្ចឹមឪពុកវាមិនរស់ទៀតណាស់ ខ្លាចឪវាទៅមុនបាត់ទៀត គាត់ចាស់ៗអស់ហើយឃើញទេ។

ក៖ មីងមានអីផ្តាំផ្ញើរបន្ថែមទេ?

ខ៖ អត់មានអីផង។

ក៖ អញ្ចឹងមានតែប៉ុន្នឹងឯងណ៎ អញ្ចឹងសូមអរគុណ សូមជម្រាបលានាក់មីង។

ខ៖ ចាស់! ជំរាបលា។